ជំពូកទី8 សន្និដ្ឋាន និងអនុសាសន៍

ឆ្លងតាមការសិក្សាបានបង្ហាញថា គំរោងនេះ គឺជាការបូមល្បាប់ខ្សាច់ដើម្បីបង្កើតឃ្លងនាវាចេញចូលសម្រាប់កំពង់ផែអន្តរជាតិកំពត ហើយល្បាប់ដែលបូមបាន គឺត្រូវបានយកទៅចាក់នៅតំបន់ចាក់បំពេញសម្រាប់បង្កើតតំបន់សេដ្ឋកិច្ចពិសេសកំពត និងកំពង់ផែអន្តរជាតិកំពត នៅឃុំបឹងទូក និងឃុំកោះតូច ស្រុកទឹកឈូ ខេត្តកំពត។ គំរោងបូមបង្កើតឃ្លងនាវាចរនេះ មានប្រវែងសរុបប្រមាណ33គ.ម មានក្រលាផ្ទៃប្រមាណ1,508ហិកតា ដែលនឹងបូមឲ្យមានជម្រៅប្រមាណ14មធៀបនឹងនីវ៉ូទឹកសមុទ្រ ហើយសំណល់ដែលបូមបាន នឹងយកទៅចាក់នៅតំបន់ចាក់បំពេញដែលមានក្រលាផ្ទៃប្រមាណ1,449ហិកតា។ ទីតាំងគំរោងជាប់ពាក់ព័ន្ធនឹង9ភូមិ ក្នុង3ឃុំ គឺឃុំបឹងទូក(ភូមិរលួស) ឃុំកោះតូច (ភូមិគីឡូ12 ភូមិព្រៃកចេក ភូមិកណ្តាល ភូមិព្រៃកអំពិល) និងឃុំព្រៃកន្ទោត(ភូមិត្រពាំងរពៅ ភូមិព្រៃកក្រែង ភូមិព្រៃ-ន្ទោត ភូមិចង្ហោន)។

ទីតាំងបូមបង្កើតឃ្លងនេះ ចាប់ផ្តើមពីចុងខាងត្បូងនៃតំបន់ចាក់បំពេញ(អនាគតជាកំពង់ផែ) ហើយឆ្ពោះមកមាត់ទ្វារកោះសេះ (ចន្លោះកោះសេះ និងកោះត្រល់)ដែលមានជម្រៅជ្រៅល្មមសម្រាប់នាវាធំៗចេញចូល។ សណ្ឋានបាតសមុទ្រក្នុង និងក្បែរតំបន់គំរោង មានជម្រាលទាបហើយវែងពីច្រាំងទៅលំហសមុទ្រ ដែលបាតសមុទ្រតំបន់បូមមានជម្រៅប្រមាណ2ម-10ម។ នៅតំបន់បូមនេះ ទឹកមានល្បឿនប្រមាណ3-6ស.ម/វិ ពេលទឹកជោរ-នាច និង6-13ម/វិ ពេលទឹកជោ-នាចក្នុងល្បឿនលឿនបំផុត។ ក្រោយពេលបូមហើយ ទិសចរន្តទឹក និងរយៈកំពស់ផ្ទៃសមុទ្រ ពុំមានការប្រែប្រួលគួរឲ្យកត់សំគាល់ឡើយ តែល្បឿនទឹកមានការកើនឡើងនៅតាមឃ្លង ហើយថយចុះតិចតួចនៅតំបន់មួយចំនួន។ ពេលដំណើរការគំរោង ការសាយភាយភាគល្អិតក្នុងរយៈពេល1អាទិត្យអាចសាយភាយជាអតិបរមាដល់ព្រំដែលមានបង្គោលដាំសារាយ ក្នុងកំហាប់ប្រមាណ5-6% តែមិនសាយភាយដល់ច្រាំងឡើយ។ គុណភាពទឹកបច្ចុប្បន្ន មានប៉ារ៉ាម៉ែត្រមួយចំនួនមានកម្រិតស្ថិតនៅក្រៅស្តង់ដា។ ចំណែកឯកម្រិតសម្លេងនៅក្បែរតំបន់ចាក់បំពេញនាពេលបច្ចុប្បន្ន ស្ថិតនៅក្រោមស្តង់ដា។

នៅជាប់ខាងជើងធ្មៀងខាងកើតតំបន់ចាក់បំពេញ មានព្រៃកោងកាង(ដែលមានដើមកោងកាង និងដើមក្រញ្ជិបដុះលាយឡំគ្នា)ប្រមាណ35ហិកតា(គណនាតាមផែនទីJICA 2002) ដែលព្រៃនេះនឹងត្រូវបាត់បង់ដោយការចាក់បំពេញ ហើយក្រៅពីនោះនៅក្បែរតំបន់គំរោងមានព្រៃកោងកាងដោយកន្លែងស្ថិតនៅតាមបណ្តោយឆ្នេរ។ តាមការសម្ភាសន៍ នៅភូមិកណ្តាល ភូមិព្រៃកអំពិល ភូមិចង្ហោន និងភូមិព្រៃកន្ទោត ព្រៃកោងកាងមានការកើនឡើងដោយសារមានការអភិរក្ស រីឯ នៅភូមិរលួស ភូមគីឡូ12 ភូមិព្រៃកចេក ភូមិព្រៃកក្រែង និងភូមិត្រពាំងរពៅ មានការថយចុះដោយសារការកាប់ឆ្កា និងការចាក់ដីបំពេញឆ្នេរ។

ចំរោះស្មៅសមុទ្រ ហាននៅច្រើនកន្លែងនៅតំបន់គំរោង ដែលក្នុងនោះតំបន់គំរោងស្ថិតនៅលើវាលស្មៅសមុទ្រទំហំប្រមាណ2,036ហ.តក្នុងចំណោមស្មៅសមុទ្រ25,240ហ.តក្នុងខេត្តកំពត។ ដោយឡែកស្មៅសមុទ្រដែលអាចរងនូវការប៉ះពាល់ដោយប្រយោល(ដោយសារការសាយភាយកំទេចកំណក្នុងចំងាយ1គ.មពីទីតាំងចាក់បំពេញ ក្នុងករណីមិនមានទំនប់ការពារ) មានប្រមាណ679.0ហ.ត។ ស្មៅសមុទ្រមានការកើនឡើងនៅភូមិកណ្តាល ភូមិព្រៃកអំពិល ភូមិចង្ហោន និងភូមិព្រៃកន្ទោត តែមានការថយចុះនៅភូមិរលួស ភូមិគីឡូ12ភូមិព្រៃកចេក ភូមិត្រពាំងរពៅ និងភូមិព្រៃកក្រែង។

នៅប្រមាណ1គ.មពីតំបន់គំរោងមានវាលដាំសារាយមួយ ដែលតំបន់បង្គោលដាំសារាយមានផ្ទៃតិចជាង1,260ហិកតា។ មេភូមិបានបង្ហាញថា ការដាំសារាយមាននៅភូមិព្រៃកចេក(7គ្រួសារ=5%ក្នុងភូមិ) ភូមិកណ្តាល(120គ្រួសារ=61%ក្នុងភូមិ) និងភូមិព្រៃកអំពីល(20គ្រួសារ=5%ក្នុងភូមិ)។ ក្នុងចំណោមប្រជាពលរដ្ឋឃុំកោះតូច94នាក់ដែលបានសម្ភាសន៍ មានអ្នកដាំសារាយជារបរបន្ទាប់បន្សំចំនួន១០1គ្រួសារក្នុងភូមិព្រៃកចេកមាន(10%) 5គ្រួសារក្នុងភូមិកណ្តាល

(36%) និង20ភ្ជួសារក្នុងភូមិព្រៃកអំពិល(65%)។ នាពេលបច្ចុប្បន្ន ចំនួនប្រជាពលរដ្ឋដាំសាវាយមានការថយចុះ ដែលអាចបណ្តាលមកពីអាកាសធាតុក្តៅពេកធ្វើឲ្យសាវាយរលួយ ពូជក្លាយ ការចាក់ឱ្យាច់សង់កំពង់ផែដែលធ្វើឲ្យទឹកល្អក់នាំឲ្យសាវាយលូតលាស់មិនល្អ(ក្រិន) និងត្រីស៊ីសាវាយ។

តាមផែនទីរដ្ឋបាលជលផល2004 ប្រមាណ1គ.មពីគំរោងមានតំបន់ផ្កាថ្ម ប៉ុន្តែតាមការអង្កេតជាក់ស្តែងមានកន្លែងខ្លះពុំឃើញមានវត្តមានផ្កាថ្មឡើយ ហើយនៅចំណុចមួយចំនួនក្រៅតំបន់នេះ គឺប្រទះឃើញមានវត្តមានផ្កាថ្មខ្លះៗ ដែលដុះប្រមាណ1-2គុម្ពផងដែរ។ តំបន់ដែលមានវត្តមានផ្កាថ្មនេះគឺវានូវឥទ្ធិពលពីគំរោងបូមប្រហាក់ប្រហែលនឹងការដាំសាវាយដែរ។ ផ្កាថ្មដែលអាចរងនូវការប៉ះពាល់ដោយប្រយោលទំហំប្រមាណ49.68ហ.ត ក្នុងករណីមិនមានទំនប់ការពារ និងការសាយភាយកំទេចកំណក្នុងចំងាយ1គ.មពីទីតាំងចាក់បំពេញ។

នៅក្នុង និងក្បែរតំបន់គំរោង និងតំបន់ចាក់បំពេញឃើញមានវត្តមានពពួកវាសិត្វចំនួន150ប្រភេទ ក្នុងនោះត្រីមាន85ប្រភេទ បង្កងមាន3ប្រភេទ បង្គាមាន6ប្រភេទ មឹកមាន6ប្រភេទ ក្តាមមាន19ប្រភេទ។ ក្នុងនោះមានប្រភេទត្រីមានតំលៃសេដ្ឋកិច្ចលើទីផ្សារមានចំនួន12ប្រភេទ(ត្រីតុកកែ ត្រីកន្ទាំង ត្រីកន្ទាំងក្រអូប ត្រីកាដី ត្រីគោ ត្រីឆ្លាមតុកកែ ត្រីត្រសក់ ត្រីស្រកាក្រាស់ ត្រីក្ងែកធំ ត្រីអូច ត្រីគ្រាប់ខ្ទុរ និងត្រីបោះត្រា)។ ក្នុងចំណោមសត្វដែលមានវត្តមានទាំងនេះ វាអាចទទួលរងនូវការបាត់បង់ពេលគំរោងដំណើរការ ជាពិសេសពពួកសត្វដែលផ្លាស់ទីយឺត និងរស់នៅស្រទាប់បាតប្រមាណ26ប្រភេទក្នុងតំបន់គំរោង និងតំបន់ចាក់បំពេញ។

ស្របជាមួយគ្នានោះផងដែរមានប្រជាពលរដ្ឋធ្លាប់បានជួបប្រទះសត្វកម្រដូចជាល្ម៉ូច ជ្រូកទឹក ផ្សោត(តាមការសម្ភាសន៍ ក្នុងចំណោមប្រជាពលរដ្ឋ215នាក់ មាន5នាក់ ក្នុងភូមិគីឡូ12 ភូមិព្រៃកក្រែង និងភូមិត្រពាំងរពៅ) ដែលគ្រាន់តែឆ្លងកាត់តែប៉ុណ្ណោះ។

ពេលប្រតិបត្តិគំរោងអាចផ្តល់ការងារដល់ជូនអ្នកក្នុងស្រុក(ប្រមាណ100នាក់) និងអ្នកចំណូលស្រុក(ប្រមាណ300នាក់) ហើយគំរោងបូមនេះនឹងបង្កើតផ្លូវនាវាចដែលអាចឲ្យវាធំៗចេញចូលបានហើយផ្តល់ជាល្បាប់ឱ្យាច់សម្រាប់ចាក់បំពេញតំបន់ចាក់បំពេញ ដែលជួយ៖

- កាត់បន្ថយដល់ការបូមយកពីតំបន់ផ្សេងទៀត ដូចជាពីជីភ្ជុ ជីបាតព្រែក-ទន្ល ឬសមុទ្រជាដើម
- ផ្តល់ល្បាប់ជាវត្ថុធាតុដើមសម្រាប់ការចាក់បំពេញ ដែលអាចជួយពន្លឿនសកម្មភាពចាក់បំពេញ ឲ្យខិតទៅកាន់តែជិតការអភិវឌ្ឍន៍បន្ថែមទៀត
- លក្ខណៈបរិស្ថានក្នុងការចាក់ប្រសើរជាងការប្រើវត្ថុធាតុដើមផ្សេងទៀត ព្រោះការប្រើប្រាស់ល្បាប់បាតសមុទ្រគឺប្រសើរជាងការយកដីទ្វីប ភ្ជុ ឬបាតបឹង-ទន្ល ដែលមានលក្ខណៈខុសគ្នានឹងសមុទ្រមកចាក់

ទន្ទឹមនឹងតួកន្លានុពលទាំងនេះ គំរោងត្រូវអនុវត្តវិធានការកាត់បន្ថយដែលមានបញ្ជាក់ក្នុងរបាយការណ៍ ឲ្យបានជាអតិបរមា ដើម្បីកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានឲ្យមកដល់កម្រិតអប្បរមា ក្នុងគោលបំណងអភិវឌ្ឍគំរោងឲ្យស្របនឹងការថែរក្សា និងការពារបរិស្ថាន។

ជាអនុសាសន៍បន្ថែម ម្ចាស់គំរោងត្រូវជ្រើសរើសក្រុមហ៊ុនសំណង់ទទួលម៉ៅការបូម និងចាក់ ដែលអាចបំពេញលក្ខខណ្ឌដូចមានបង្ហាញក្នុងជំពូកទី6 ចំនុចអនុសាសន៍ពីក្រុមការងារCES ដូចជាការជ្រើសរើសគ្រឿងចក្របូម ដែលមានប្រសិទ្ធិភាពខ្ពស់ ការរាយរាំងនន្ទកករ ការបំពាក់ប្រព័ន្ធតាមដានភ្លាមៗពេលកំពុងបូម បច្ចេកទេសចាក់ បំពេញដែលមានបាតគ្រឹះមាំនិងកាត់បន្ថយការសាយភាយកករ ការច្រោះទឹកមុននឹងបង្ហូរត្រលប់ទៅសមុទ្រជាដើម។ ទន្ទឹមនឹងនោះ ម្ចាស់គំរោងត្រូវមានរបាយការណ៍បៃតង(Green Report)សម្រាប់សាធារណជនដឹងអំពីស្ថានភាពបរិស្ថាន និងសកម្មភាពចូលរួមក្នុងសង្គមរបស់ក្រុមហ៊ុនផងដែរ។

ជាទីបញ្ចប់ក្រុមហ៊ុន កំពត ផត ដែលជាម្ចាស់គំរោងនេះ ផ្តល់នូវប្រយោជន៍ច្រើនដល់រដ្ឋាភិបាល និងសង្គម ដែលគំរោងនេះ ជាបច្ច័យយ៉ាងធំធេងសម្រាប់ការជំរុញគំរោងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសកំពត និងកំពង់ផែអន្តរជាតិកំពតឲ្យកាន់តែឆាប់លេចចេញជារូបរាង ដែលនឹងជួយលើកកំពស់តំបន់លើច្រើនវិស័យ រួមទាំងវិស័យដឹកជញ្ជូនតាមផ្លូវទឹក ឧស្សាហកម្ម ទេសចរណ៍ សុខាភិបាល អប់រំ ជាពិសេសគឺបង្កើតការងារសម្រាប់ប្រជាពលរដ្ឋក្នុង និងក្រៅតំបន់។

ក្នុងនោះក្រុមហ៊ុន កំពត ផត សូមសំណូមពរដល់ក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធនានា មេត្តាអនុញ្ញាតជួយជ្រោមជ្រែង និងផ្តល់លក្ខណៈងាយស្រួលដល់ក្រុមហ៊ុន ដើម្បីអនុវត្តគំរោងបូមខ្សាច់បង្កើតយ្លងនាវាចេញចូល និងចាក់ខ្សាច់បំពេញតំបន់សេដ្ឋកិច្ចពិសេសកំពត និងកំពង់ផែអន្តរជាតិកំពត ឲ្យបានសមស្រpបនឹងច្បាប់កិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា។

បានឃើញ និងទទួលស្គាល់ខ្លឹមសារបាយការណ៍	បានឃើញ និងទទួលស្គាល់ខ្លឹមសារបាយការណ៍
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ2010	រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ2010
ម្ចាស់គំរោង ៖ ក្រុមហ៊ុន កំពត ផត	រៀបចំរបាយការណ៍ដោយ ៖ ក្រុមហ៊ុន ស៊ី អ៊ី អេស
ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា
នាយកក្រុមហ៊ុន	នាយកក្រុមហ៊ុន
១	២

NEAM KOPY